**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ០២១/២១ ក.ប/ស.ណ.ន.ខ.ល

**ក្រសួងពាណិជ្ជកម្ម**

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាលើវិស័យនាំចេញវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និង ផលិតផលធ្វើដំណើរនិងកាបូប

យោងប្រកាសអន្តរក្រសួងលេខ៣៦៤/២០ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ស្តីពីការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាលើវិស័យនាំចេញវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និងផលិតផលធ្វើដំណើរនិងកាបូប និងយោងអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការអន្តរជាតិខាងការងារ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្ម សូមធ្វើការណែនាំដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ព្រមទាំងការិយភារីនៃផ្នែកវាយនភណ្ឌនិងកាត់ដេរសម្លៀកបំពាក់ និងរោងចក្រ សហគ្រាសផលិតផលិតផលធ្វើដំណើរនិងកាបូបទាំងអស់ ដែលស្នើសុំចុះបញ្ជីទទួលសិទ្ធិនាំចេញទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ស្របតាមប្រកាសលេខ២៣២ ព.ណបអព.ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទចុះបញ្ជីទទួលសិទ្ធិនាំចេញទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ត្រូវអនុវត្តដូចខាងក្រោម៖

១. ចុះបញ្ជីជាមួយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (Better Factories Cambodia - BFC) ជាមុនសិន។ លោក លោកស្រី ត្រូវបង់វិភាគទានហិរញ្ញវត្ថុទ្រទ្រង់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាតាមរយៈសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ដើម្បីអាចស្នើសុំចុះបញ្ជីជាមួយគម្រោងនេះ។

២. ចាប់ពីឆ្នាំ២០២២តទៅ ត្រូវមានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារដែលចេញដោយអធិការការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបញ្ជាក់អំពីស្ថានភាពលក្ខខណ្ឌការងារប្រចាំរោងចក្រ សហគ្រាសរបស់លោក លោកស្រី ស្របតាមប្រកាសលេខ៤៣៤/២០ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ និងផែនការសកម្មភាពរួមរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្នុងករណី លោក លោកស្រីមិនបានបំពេញលក្ខខណ្ឌខាងលើ លោក លោកស្រីនឹងមិនទទួលបានសិទ្ធិនាំចេញទំនិញទៅបរទេសនោះទេ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨២៧៦៩

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីដែលជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស ព្រមទាំងការិយភារីនៃផ្នែកវាយនភណ្ឌនិងកាត់ដេរសម្លៀកបំពាក់ និងរោងចក្រ សហគ្រាសផលិតផលិតផលធ្វើដំណើរ និងកាបូបទាំងអស់ចូលរួមអនុវត្តតាមសេចក្ដីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ៥កើត ១១កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**